**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ  សាសនា  ព្រះមហាក្សត្រ**

**ក្រសួងរៀបចំដែនដី  នគរូបនីយកម្ម  និង  សំណង់**
**អ្នកនាំពាក្យ**

# សេចក្តីប្រកាសព័ត៌មាន

កាលពីថ្ងៃទី ១៧ ខែ មីនា ឆ្នាំ ២០១០ វេលាម៉ោង ៩:០០   នាបរិវេណដីសហគមន៍ជនជាតិដើមភាគតិចទំពួន ដែលស្ថិតនៅក្នុងភូមិល្អឺនក្រែន ឃុំអូរជុំ ស្រុកអូរជុំ ខេត្តរតនគិរី  ឯកឧត្តមទេសរដ្ឋមន្ត្រី **អ៊ឹម ឈុនលឹម** រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់  និងជាប្រធានក្រុមប្រឹក្សាគោលនយោបាយដីធ្លី  បានដឹកនាំគណៈប្រតិភូមួយក្រុមរបស់ក្រសួង ចុះសាកសួរសុខទុក្ខបងប្អូនជនជាតិភាគតិច និងស្វែងយល់ជាក់ស្តែងអំពីវឌ្ឍនភាពនៃដំណើរការសាកល្បងការចុះបញ្ជីដីជាកម្មសិទ្ធិសមូហភាពជូនសហគមន៍ជនជាតិដើមភាគតិច   ដែលក្រុមការងាររបស់ក្រសួងបាន និងកំពុងអនុវត្តជូនសហគមន៍ជនជាតិដើមភាគតិចទំពួនតាមសំណើរបស់សហគមន៍ ។ វត្តមានទទួលស្វាគមន៍ឯកឧត្តមទេសរដ្ឋមន្ត្រី       មានឯកឧត្តម **មួង ប៉យ** ប្រធានក្រុមប្រឹក្សាខេត្ត ឯកឧត្តម ប៉ាវ ហាមផាន អភិបាលខេត្ត និងឯកឧត្តម លោកជំទាវ លោកស្រី អស់លោកជា  រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ អគ្គនាយក  ប្រធាននាយកដ្ឋាន   និងអង្គភាពមួយចំនួនជុំវិញក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់  និងជុំវិញសាលាខេត្ត សរុបប្រមាណ ៥០នាក់ ហើយនឹងបងប្អូនជនជាតិដើមភាគតិចទំពួន ដែលជាសមាជិករបស់សហគមន៍ទាំង ៨៨ គ្រួសារ ។

ឯកឧត្តម **ប៉ាវ ហាមផាន** ក្នុងមតិស្វាគមន៍របស់ឯកឧត្តម ឯកឧត្តមបានឱ្យដឹងថា សហគមន៍ជនជាតិដើមភាគតិចទំពួន នៅក្នុងខេត្តរតនគិរី មាន ០២ សហគមន៍ដែលបានបង្កើតឡើង   និងមានការទទួលស្គាល់ជាផ្លូវការរួចហើយពីក្រសួងមហាផ្ទៃ តាំងពីឆ្នាំ ២០០៩ គឺ០១សហគមន៍នៅក្នុងភូមិល្អឺនក្រែន ឃុំអូរជុំ ស្រុកអូរជុំ មាន ៨៨គ្រួសារ និងមនុស្ស ៤០៥ នាក់ និង០១ សហគមន៍ទៀត នៅក្នុងភូមិឡាអិន   ឃុំតឺន  ស្រុកកូនមុំ   មាន ១០៨គ្រួសារ និង ៤៣០នាក់ ។   ដោយអនុលោមតាមច្បាប់ភូមិបាល  និងអនុក្រឹត្យលេខ ៨៣ អនក្រ.បក ចុះ ថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ ២០០៩   ស្តីពីនីតិវិធីនៃការចុះបញ្ជីដីសហគមន៍ជនជាតិដើមភាគតិច និងតាមសំណើរបស់សហគមន៍ជនជាតិដើមភាគតិចទាំង ០២ ក្រុមការងាររបស់ខេត្ត  ដោយមានជំនួយគាំទ្របច្ចេកទេសពីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់  និងជំនួយថវិកាពីអង្គការ GTZ  បានដំណើរការចុះបញ្ជីដីធ្លីជាកម្មសិទ្ធិសមូហភាពរបស់សហគមន៍ទាំងពីរ ដោយមានលទ្ធផល :

- ភូមិល្អឺនក្រែន មានផ្ទៃដីសរុប ៩១៣ហិកតា ប្រើប្រាស់បង្គោលរឹងមាំបោះសំគាល់ព្រំដីសរុប ១៤០ បង្គោល
- ភូមិឡាអិន មានផ្ទៃដីសរុប ១.៨៥៤ហិកតា ប្រើប្រាស់បង្គោលសរុប ២៦១បង្គោល ។

មកដល់បច្ចុប្បន្ន ក្រុមការងារកំពុងដំណើរការវាស់វែងទំហំដីជាក់ស្តែង ។ ក្រោយការវាស់វែងនេះ ទិន្នន័យដែលរកឃើញ នឹងត្រូវធ្វើការបិទផ្សាយជាសាធារណៈក្នុងរយៈពេល ០១ខែ  ជូនគ្រប់អ្នកពាក់ព័ន្ធ ទាំងរដ្ឋ ទាំងឯកជន  ទាំងសហគមន៍ជិតខាងដែលមានព្រំប្រទល់ដីជាប់សហគមន៍ទាំងពីរ  ទាំងសមាជិកក្នុងសហគមន៍នេះផ្ទាល់  ដើម្បីធ្វើការផ្ទៀងផ្ទាត់  ឬមានការតវ៉ាផ្សេងៗ  មុននឹងធ្វើការចុះបញ្ជីក្នុងសៀវភៅគោលបញ្ជីដីធ្លី  និងចេញប័ណ្ណសំគាល់សិទ្ធិជូនសហគមន៍ទាំងពីរជាផ្លូវការ ។  ឯកឧត្តមអភិបាលខេត្តបានបញ្ជាក់ថា   ការបោះបង្គោលព្រំដី   ធ្វើឡើងតាមការចង្អុលបង្ហាញរបស់សហគមន៍ផ្ទាល់    ។  សហគមន៍មានការ

ចូលរួម និងសំដែងការរីករាយសាទរ ចំពោះលទ្ធផលនៃការវាស់វែង ដោយពួកគាត់បានទទួលការគាំពារដីរបស់សហគមន៍កាន់តែរឹងមាំតាមផ្លូវច្បាប់។

មានមតិសំណេះសំណាល ឯកឧត្តមទេសរដ្ឋមន្ត្រីបានសំដែងការអបអរសាទរ និងស្ងើចសរសើរចំពោះជំហានវិវឌ្ឍន៍ដែលក្រុម ការងារខេត្តខិតខំសំរេចបាននូវលទ្ធផលគួរមោទនៈនេះ។ ឯកឧត្តមបានបញ្ជាក់ផងដែរថា ការចុះបញ្ជីដីជូនសហគមន៍ជនជាតិដើមភាគតិច ជាគោលនយោបាយអាទិភាពរបស់រាជរដ្ឋាភិបាល ពិសេសសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និងក៏ជាកិច្ចការថ្មីសំរាប់កម្ពុជា ក៏ដូចជាប្រទេសក្នុងតំបន់ផងដែរ ដែលមកដល់ពេលនេះ មិនទាន់មានប្រទេសណាមួយដែលមានជនជាតិដើមភាគតិច ហើយបានផ្តល់ដីធ្លីធ្វើជាកម្មសិទ្ធិសមូហភាពដូចនៅកម្ពុជានោះឡើយ បើនឹងផ្តល់ក៏ផ្តល់ឱ្យត្រឹមសិទ្ធិប្រើប្រាស់ និងអាស្រ័យផលប៉ុណ្ណោះ ឯសិទ្ធិចាត់ចែងគឺរដ្ឋ។ ឯកឧត្តមបានធ្វើការកត់សំគាល់ដែរថា ក្រៅពីសហគមន៍ ០២នេះ ក៏មានសហគមន៍ ០១ទៀតដែរនៅខេត្តមណ្ឌលគីរី គឺសហគមន៍ជនជាតិព្នងចំនួន ១០៤ គ្រួសារ ស្មើ ៤១២នាក់ នៅភូមិអណ្តូងក្រឡឹង ឃុំសែនមនោរម្យ ស្រុកអូរ៉ាំង ដែលមកទល់ពេលនេះ យើងបានបញ្ចប់ការបោះបង្គោល និងវាស់វែងក្បាលដីរួចជាស្ថាពរហើយ ដោយប្រើប្រាស់បង្គោលព្រំជាង ៥០០បង្គោល លើផ្ទៃដីសរុបចំនួន ១.៣៧៣ ហិកតា ក្នុងនោះមានដីព្រៃតំណម ជាង ៧ ហិកតា ដីព្រៃកប់ខ្មោចជាង ៦ហិកតា ដីស្រែជាង ១៣ហិកតា ដីលំនៅឋានជាង ១៥៩ហិកតា និងដីចំការ ជាង ១.១៨៦ហិកតា។ ឯកឧត្តមទេសរដ្ឋមន្ត្រីបានសង្កត់ធ្ងន់ថា អ្វីដែលលំបាកនោះ គឺស្ថានភាពដីរបស់សហគមន៍ស្ថិតក្នុងព្រៃក្រាស់ មានទំហំធំ ឆ្លងកាត់ជ្រោះជ្រលងដងអូរ ឯបរិមាណមន្ត្រីវាស់វែងមានចំនួនតិច ដែលមិនមែនជាការងាយស្រួលឡើយនៅក្នុងការវាស់វែង និងការបោះបង្គោលព្រំដី ពិសេសបង្គោលព្រំដីមួយៗមានទម្ងន់ធ្ងន់ គ្មានផ្លូវដឹកជញ្ជូនទៅដល់ ក្រៅតែពីការប្រើកំលាំងមនុស្សឱ្យលីសែងដើម្បីបានបង្គោលទាំងនោះទៅបោះតាមគោលដៅ។ ឯតម្លៃបង្គោលមួយៗមានពី ២៥ ទៅ ៣០ដុល្លារ ហើយមួយសហគមន៍ៗត្រូវប្រើបង្គោល ១៤០ ទៅជាង ៥០០បង្គោល។ ដូច្នេះការងារនេះ មិនមែនសាមញ្ញឡើយ គឺទាមទារឆន្ទះ និងការយកចិត្តទុកដាក់ខ្ពស់ណាស់ពីគ្រប់ថ្នាក់ពាក់ព័ន្ធ ពិសេសពីអាជ្ញាធរដែនដី និងមន្ត្រីជំនាញរបស់យើង ហើយដែលក្រោយពីបញ្ចប់ការសាកល្បងនៅក្នុង ភូមិទាំង ០៣ ក្រសួង និងអជ្ញាធរដែនដីត្រូវបន្តសហការអនុវត្តការងារនេះក្នុងក្របខណ្ឌទូទាំងប្រទេស ក្នុងតំបន់ដែលមានសហគមន៍ជនជាតិដើមភាគតិច ដែលបានបង្កើតឡើង និងមានការទទួលស្គាល់ជាផ្លូវការពីក្រសួងមហាផ្ទៃ ពិសេសនៅក្នុងខេត្តរតនគិរី គឺមាន ០៣សហគមន៍ទៀតដែលទើបបង្កើតក្នុងឆ្នាំ ២០១០នេះ ហើយដែលខេត្តត្រូវគិតគូររៀបចំផែនការអនុវត្តន៍ និងត្រូវមានវិធានការការពារបណ្តោះអាសន្ន នៅក្នុងការបង្កកដីដែលស្ថិតក្នុងភូមិសាស្ត្ររបស់សហគមន៍ទាំង ០៣នេះ មិនឱ្យមានការបញ្ជាក់ការទិញ លក់ ដាក់បញ្ចាំ។ល។ រហូតដល់ក្បាលដីនៅទីនោះបានត្រូវចុះបញ្ជីរួច។

សូមរំលឹកថា ក្នុងគោលដៅគោរពសិទ្ធិជាប្រពៃណីរបស់ជនជាតិដើមភាគតិច ដែលមានទំលាប់រស់នៅ និងប្រើប្រាស់ដីធ្លីជាលក្ខណៈសមូហភាព ធ្វើចំការពនេចរ មានដីព្រៃអារក្ស ដីព្រៃតមជាជំនឿរបស់ខ្លួន ច្បាប់ភូមិបាលឆ្នាំ ២០០១ នៃព្រះរាជាណាចក្រកម្ពុជា មាត្រា ២៣ ដល់ ២៨ បានកំណត់ឱ្យចុះបញ្ជីដីជូនសហគមន៍ជនជាតិដើមភាគ តិចជាកម្មសិទ្ធិសមូហភាពចំពោះជនជាតិដើមភាគតិចដែលបានព្រមព្រៀងគ្នារៀបចំ និងរស់នៅជាលក្ខណៈសហគមន៍ និងមានសំណើសុំចុះបញ្ជីដីជាសមូហភាពរបស់សហគមន៍ជាផ្លូវការ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០១០